ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ១៣.១៤ ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I - ទីស្ដីការគណៈរដ្ឋមន្ត្រី

អនុក្រឹត្យ

១០-៤-១៩៩៦ អនុក្រឹត្យលេខ ១៣ អនក្រ.បក ស្ដីពីការបំពេញបន្ថែមក្នុងតារាងបៀវត្សចំពោះកាំប្រាក់នូវបណ្ណាឋានៈថ្មីសមមូលនិងកាំប្រាក់ឋានៈនាទីចាស់របស់មន្ត្រីរាជការស៊ីវិល ៦១១

០៤-៤-១៩៩៦ អនុក្រឹត្យលេខ ៥៣ អនក្រ.តត ស្ដីពីការជូនមេដាយ សហមេត្រី ៦១៣

០៤-៤-១៩៩៦ អនុក្រឹត្យលេខ ៥៤ អនក្រ.តត ស្ដីពីការជូនមេដាយ សហមេត្រី ៦១៤

០៤-៤-១៩៩៦ អនុក្រឹត្យលេខ ៥៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦១៥

០៤-៤-១៩៩៦ អនុក្រឹត្យលេខ ៥៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦១៧

០៤-៤-១៩៩៦ អនុក្រឹត្យលេខ ៥៧ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦១៨

០៥-៤-១៩៩៦ អនុក្រឹត្យលេខ ៥៨ អនក្រ.តត ស្ដីពីការឱ្យចូលនិវត្តន៍មន្ត្រីរាជការ ៦១៩

១០-៤-១៩៩៦ អនុក្រឹត្យលេខ ៥៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦២០

១០-៤-១៩៩៦ អនុក្រឹត្យលេខ ៦០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦២១

I - ការងារបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

០១-៤-១៩៩៦ ប្រកាសលេខ ២៥១ ផក.ប្រក អនុញ្ញាតឱ្យលោក ហេង ឡេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មផលិតអាល់កុល « សញ្ញានាគពីរ » ៦២៣

០១-៤-១៩៩៦ ប្រកាសលេខ ២៥៤ ផក.ប្រក អនុញ្ញាតឱ្យលោក អ៊ុង ប៉េងត្រី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មស្រាកែថ្ម ៦២៤
០១-៤-១៩៩៦ ប្រកាសលេខ ២៦៥ ផក.ប្រក អនុញ្ញាតឱ្យអ្នកស្រី ហាក់ ជូ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០ សេះ ៦២៤
០១-៤-១៩៩៦ ប្រកាសលេខ ២៦៦ ផក.ប្រក អនុញ្ញាតឱ្យលោក កាង ធី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ ៦២៥
០១-៤-១៩៩៦ ប្រកាសលេខ ២៦៧ ផក.ប្រក អនុញ្ញាតឱ្យអ្នកស្រី សៅ សុផល ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ ៦២៦
០១-៤-១៩៩៦ ប្រកាសលេខ ២៦៨ ផក.ប្រក អនុញ្ញាតឱ្យលោក ធីង ប៊ុនហាំ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៥០ សេះ ៦២៦
០១-៤-១៩៩៦ ប្រកាសលេខ ២៦៩ ផក.ប្រក អនុញ្ញាតឱ្យលោក អ៊ុំ ហេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តសិប្បកម្មផលិតទឹកស៊ីអ៊ីវខាប់ ទឹកម្ទេស និងទឹកសៀង « សុវណ្ណភូមិ » ៦២៧
០១-៤-១៩៩៦ ប្រកាសលេខ ២៧០ ផក.ប្រក អនុញ្ញាតឱ្យអ្នកស្រី អ៊ួច សុខា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធ សញ្ញា « រូបផ្កាយ » ៦២៨
០២-៤-១៩៩៦ ប្រកាសលេខ ២៧១ បល.ប្រក ស្តីពីការបង្កើតអង្គភាពទឹកស្អាត ៦២៨
០៨-៤-១៩៩៦ ប្រកាសលេខ ២៩៨ ផក.ប្រក អនុញ្ញាតឱ្យលោក ហោ តឹមសៀង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០ សេះ ៦៣០

ត

០៨-៤-១៩៩៦	ប្រកាសលេខ ២៩៩ ផក.ប្រក អនុញ្ញាតឱ្យអ្នកស្រី តាន់ ម៉ាលី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១០០ សេះ	៦៣០
០៨-៤-១៩៩៦	ប្រកាសលេខ ៣០០ ផក.ប្រក អនុញ្ញាតឱ្យលោក អ៊ិត សំហេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥០ សេះ	៦៣១
០៨-៤-១៩៩៦	ប្រកាសលេខ ៣០១ ផក.ប្រក អនុញ្ញាតឱ្យលោក ហ៊ុន វិបុល ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០ សេះ	៦៣២
០៨-៤-១៩៩៦	ប្រកាស លេខ ៣០២ ផក.ប្រក អនុញ្ញាតឱ្យលោក ជាំ ស ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ផ្ទេរភារកិច្ចគ្រប់គ្រងរោងម៉ាស៊ីនកិនស្រូវជូនលោក ចៅ សៀវ វិញ	៦៣២
០៨-៤-១៩៩៦	ប្រកាសលេខ ៣០៣ ផក.ប្រក អនុញ្ញាតឱ្យលោក សេង សារឿន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការផលិតទឹកស៊ីអ៊ីវខាប់ សញ្ញា « មេអំបៅ »	៦៣៣
០៨-៤-១៩៩៦	ប្រកាសលេខ ៣០៤ ផក.ប្រក អនុញ្ញាតឱ្យលោក ស៊ឹម ស៊ុយតាំង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មស្រាកែច្នៃ	៦៣៤
០៨-៤-១៩៩៦	ប្រកាសលេខ៣០៥ ផក.ប្រក អនុញ្ញាតឱ្យលោក អ៊ុង រស្មីអាម៉េត ជនជាតិថៃ បើកដំណើរការឧស្សាហកម្មតូចផលិតចំណីសត្វ	៦៣៤
០៨-៤-១៩៩៦	ប្រកាសលេខ ៣០៦ ផក.ប្រក អនុញ្ញាតឱ្យអ្នកស្រី លី ច្រឹប ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការឧស្សាហកម្មផលិតទឹកបរិសុទ្ធសញ្ញា « មុដពេជ្រ »	៦៣៥

២ - លិខិតការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

០១-៤-១៩៩៦	ប្រកាសលេខ ៣០១ អយក.ប្រក ស្តីពីការផ្លាច់សាលាឧបសម្ព័ន្ធមកជាសាលាបឋមសិក្សាពេញលក្ខណៈ	៦៣៦
០៣-៤-១៩៩៦	ប្រកាសលេខ៣១៣ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យទីរួមខេត្តបាត់ដំបង ទៅជា «អនុវិទ្យាល័យ សោហ៊ី » ស្ថិតនៅក្នុងស្រុកស្វាយប៉ោ ខេត្តបាត់ដំបង	៦៣៨

I - ទីស្ដីការគណៈរដ្ឋមន្ត្រី

អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៣ អនក្រ.បក

ស្ដីពីការបំពេញបន្ថែមក្នុងតារាងបៀវត្ស

ចំពោះការប្រាក់នូវបណ្ណាថ្នាក់ៈថ្មីសមមូលនឹង

ការប្រាក់ថ្នាក់ៈ នាទីចាស់របស់មន្ត្រីរាជការស៊ីវិល

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច **នរោត្តម សីហានុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញសេចក្ដីសំរេចលេខ៨៩ សសរ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ ១៩៨៣ ស្ដីពីប្រព័ន្ធបៀវត្ស កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ
- បានឃើញអនុក្រឹត្យលេខ០៥ អនក្រ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩២ ស្ដីពីការកែលំអ បៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ

– យោងសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សំរេច

មាត្រា ១ : ត្រូវបានបំពេញបន្ថែមក្នុងតារាងកាំប្រាក់ «ក២» ដែលបាននិងកំពុងអនុវត្តសព្វថ្ងៃនូវ បណ្ណោឋាន:នាទីថ្មីបច្ចុប្បន្នរបស់មន្ត្រីរាជការស៊ីវិល ទៅតាមមុខងារ និងកាំប្រាក់ក្នុងតារាងដូចខាងក្រោម :

ប្រភេទ	បៀវត្ស	មុខងារចាស់	មុខងារថ្មី
ក II.1	៧១.០០០៛	–ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី	–នាយករដ្ឋមន្ត្រី
ក II.2	៦៤ ៧០០៛	–អនុប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី	–ឧបនាយករដ្ឋមន្ត្រី
ក II.3	៦០.០០០៛	–រដ្ឋមន្ត្រី	–ទេសរដ្ឋមន្ត្រី –រដ្ឋមន្ត្រី និង ថ្នាក់ស្មើ
ក II.4.3	៥៧ ៦០០៛	–ប្រធានអគ្គនាយកចំណុះគណរដ្ឋមន្ត្រី	–រដ្ឋលេខាធិការ និង ថ្នាក់ស្មើ
ក II.4.1 ក II.4.2	៥២.៩០០៛ ៥៥ ៣០០៛	–អនុរដ្ឋមន្ត្រី –ប្រធានគណ:កម្មាធិការប្រជាជនបដិវត្តខេត្ត–ក្រុង	–អនុរដ្ឋលេខាធិការ និង ថ្នាក់ស្មើ –អភិបាលខេត្ត - ក្រុង
ក II.5.1 ក II.5.2	៤៧ ៤០០៛ ៤៩ ៧០០៛	–អនុប្រធានគណ:ប្រជាជនបដិវត្តខេត្ត - ក្រុង	–អភិបាលរងខេត្ត–ក្រុង –អគ្គនាយក អគ្គាធិការ និង ថ្នាក់ស្មើ –អគ្គលេខាធិការក្រសួង ឬរដ្ឋលេខាធិការដ្ឋាន
ក II.6.1	[illegible]២ ៦០០៛	–ប្រធាននាយកដ្ឋាន	–អគ្គនាយករង អគ្គាធិការរង –អគ្គលេខាធិការរងក្រសួង ឬរដ្ឋលេខាធិការដ្ឋាន –អធិការ
ក II.6.2	៤៤.២០០៛		–នាយកខុទ្ទកាល័យក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន –ទីប្រឹក្សារបស់ក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន

			-ប្រធាននាយកដ្ឋាន និង ថ្នាក់ស្មើ -ជំនួយការក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន
ក II.7.1	៣៩ ០០០៛	-អនុប្រធាននាយកដ្ឋាន -ប្រធានមន្ទីរជំរិញខេត្ត-ក្រុង	-អភិបាលខ័ណ្ឌ-ស្រុក
ក II.7.2	៤០ ៦០០៛	-ប្រធានគណៈកម្មាធិការប្រជាជនបរិវត្ត ខ័ណ្ឌ-ស្រុក	-នាយខុទ្ទកាល័យក្រសួង- ឬ រដ្ឋលេខាធិការដ្ឋាន

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីនៃក្រសួង និង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ | **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៥៣ អនក្រ.តត

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត ១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ អស្សឫទ្ធិ សហមេត្រី ជូនចំពោះលោកអនុសេនីយ៍ឯក SEYCHELLES MARCEL នៃក្រុមបេសកកម្មជំនួយយោធាបារាំង ប្រចាំនៅកម្ពុជា ដែលមានស្នាដៃល្អក្នុងការជួយហ្វឹកហ្វឺនដល់កងទ័ពពិសេស នៃកងយោធពលខេមរភូមិន្ទ ចំនួន ១៦០ នាក់ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៥៤ អនក្រ.តត
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ អស្សឫទ្ធិ សហមេត្រី ជូនចំពោះលោកអនុសេនីយ៍ឯក RENARD FRANCH សេនានុពន្ធយោធានៃសាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អក្នុងការលើកស្ទួយចំណងមិត្តភាព និង សហប្រតិបត្តិការយោធាបារាំង–ខ្មែរ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវ អនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៥៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ « មាស » ស្ថាបនាជាតិជូនចំពោះលោកស្រី MARIKO OKAMURA ប្រធានសមាគម ASAC ដែលបានជួយសាងសង់សាលារៀន និង ពង្រីក កម្មវិធីអប់រំផ្នែកអក្ខរកម្មនៅខេត្តកំពង់ស្ពឺ និង កំពង់ចាម អស់ទឹកប្រាក់សរុប ៣៥.១០០ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងនាយកខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៥៦ អនក្រ.តត

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្ដាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ « មាស » ស្ថាបនាជាតិជូនលោក **ម៉ុង ឫទ្ធី** នាយកក្រុមហ៊ុន **ម៉ុង ឫទ្ធី** ដែលបានចំណាយធនធានផ្ទាល់ខ្លួនអស់ចំនួនសរុប : ១៩៨ ៤០០ ដុល្លារសហរដ្ឋអាមេរិក សំរាប់ចូលរួមចំណែកកសាងប្រទេសជាតិ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួង

មហាផ្ទៃ និងអភិបាលខេត្តកណ្តាលត្រូវ អនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៥៧ អនក្រ.គត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តព្រៃវែង

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ «មាស» ស្ថាបនាជាតិ ជូនចំពោះសប្បុរសជន ០៤ រូប ដែលមាន ទឹកចិត្តសប្បុរសធម៌បានបរិច្ចាគធនធានផ្ទាល់ខ្លួន សរុបចំនួន

៣២១ ៦០០ ដុល្លារអាមេរិក សំរាប់កសាងសំណង់សាធារណៈផ្សេងៗ ដូចជា ព្រះវិហារ សាលារៀន ផ្លូវថ្នល់ កីឡាដ្ឋាន មន្ទីរពេទ្យ ស្ពាន ស្រះទឹក ប្រឡាយ អណ្តូង ។ល។ នៅក្នុងឃុំស៊ាងឃ្វាង ស្រុកកំចាយមារ ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោមនេះ ÷

១–ឯកឧត្តម **ញឹម វណ្ណដា**

២–លោកឧកញ៉ា **ថេង ប៊ុនម៉ា**

៣–លោក ឧកញ៉ា **សុខ គង់**

៤–លោក **ម៉ុង ឫទ្ធី**

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងអភិបាល ខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៥៨ អនក្រ.តត

ស្តីពីការអោយចូលនិវត្តន៍មន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ

វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : អោយលោក **សេង ឈួរ** កើតនៅឆ្នាំ ១៩៣៦ អភិបាលស្រុក អូយ៉ាដាវ ខេត្តរតនគីរី ចូលនិវត្តន៍ ចាប់ពីថ្ងៃទី ០១ ខែមេសា ឆ្នាំ១៩៩៦ នេះតទៅ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការមុខងារសាធារណៈ ខេត្ត រតនគីរី និង លោក **សេង ឈួរ** ត្រូវអនុវត្តអនុក្រឹត្យនេះ អោយបានសំរេច ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឬទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៥៩ អនក្រ.តត
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ

វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ «មាស» ស្ថាបនាជាតិ ជូនលោកស្រី **ហៃក ឡឹស្ម៉ន** (HEIKE LOSCHMANN) តំណាងអង្គការហៃនរីសបឺល ដែលបានជួយជួសជុលអាគារពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ និងរៀបចំសាខា បណ្ណាល័យតាមខេត្ត–ក្រុង ព្រមទាំងឧបត្ថម្ភ សម្ភារៈការិយាល័យផ្សេងៗដល់ពុទ្ធសាសនបណ្ឌិត្យ អស់ទឹកប្រាក់សរុបជាង ៥៣០ ០០០ ដុល្លារ សហរដ្ឋអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនាត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឬទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៦០ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ «មាស» ស្ថាបនាជាតិ ជូនអង្គការជំនួយ សូត្ទស៊ូ ជប៉ុន (JSRC) ដែលបានជួយកសាងសាលារៀន នៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង អស់ទឹក ប្រាក់សរុប ២២ ០០០ ដុល្លារសហរដ្ឋ អាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល ខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

II - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ២៥១ ឧក.ប្រក.ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយសិប្បកម្មផលិតអាល់កុល សញ្ញា «នាគពីរ» ដែលមានលោក **ហេង ឡេង** ជនជាតិខ្មែរ .សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១០៨៣២០ ភ.ព ចុះថ្ងៃទី ២២– ៤–១៩៨៥ ជាប្រធាន អាស័យដ្ឋាន ផ្ទះលេខ ១០ ភូមិ ១ សង្កាត់បឹងទំពុន ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ បើកដំណើរផលិតកម្មនៅក្នុងទីតាំង ផ្ទះសង់ថ្មី ផ្លូវលេខ ២៧១ ក្រុមទី ៤ សង្កាត់ បឹងសាឡាង ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ហេង ឡេង** ត្រូវបានអនុញ្ញាតអោយផលិតនូវផលិតផលអាល់កុល សញ្ញា « នាគពីរ » ស្របតាមគំរូ សញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៥៤ ឧក.ប្រក.ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **អ៊ុង ម៉េងត្រី** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១២៩៨៤៧ ប.ជ ចុះថ្ងៃទី ០៤ - ៤ - ១៩៩២ អាស័យដ្ឋាន បច្ចុប្បន្នផ្ទះលេខ ៩៥ ភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ បើកដំណើរសិប្បកម្មស្រាកែថ្នៃ នៅក្នុងទីតាំងដូចទីតាំងខាងលើ ។

ប្រការ ២ : លោក **អ៊ុង ម៉េងត្រី** ត្រូវបានអនុញ្ញាតអោយផលិតនូវផលិតផលស្រាកែថ្នៃ ចំនួន ១មុខ គឺស្រា សំពៅមាសរិស្តី សញ្ញាសំពៅមាស ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួង ឧស្សាហកម្ម រ៉ែនិងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៦៥ ឧក.ប្រក. ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ហាក់ ឌួ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៣២៤៧ ព.វ ចុះថ្ងៃទី ២៥-១២-១៩៨៥ អាស័យដ្ឋានបច្ចុប្បន្នភូមិព្រៃកខ្សាយ ឃុំព្រៃក ខ្សាយ " ក " ស្រុកពាមរក៍ ខេត្តព្រៃវែង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១២០ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **ហាក់ ជូ** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំង ដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបាន យ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់ មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុង ករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាស នេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៦៦ ឧក.ប្រក.ចុះ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ភាន ធី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់ អត្តសញ្ញាណប័ណ្ណលេខ ៤០១៥២២ ព.វ ចុះថ្ងៃទី ១២ - ០១ - ១៩៩៣ អាស័យដ្ឋាន បច្ចុប្បន្នភូមិឧត្តម ឃុំព្រែកខ្សាយ " ក " ស្រុកពាមរក៍ ខេត្តព្រៃវែង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០ សេះ នៅក្នុង ទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ភាន ធី** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំង ដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបាន យ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់ មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុង ករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាស នេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៦៧ ឧក.ប្រក. ចុះ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **សៅ សុផល** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៨២៨៦៦ ក.ស្ព ចុះថ្ងៃទី ២៣-៦-១៩៨៨ អាស័យដ្ឋានបច្ចុប្បន្នភូមិភក់ ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង៤០ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **សៅ សុផល** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៦៨ ឧក.ប្រក. ចុះ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **អ៊ឹម ប៊ុនហាំ** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២៧៨៩៦ សរ ចុះថ្ងៃទី ២៦-៧-៨៧ អាស័យដ្ឋានបច្ចុប្បន្នក្រុមទី ៣ ភូមិ សាលាកន្សែង ឃុំថ្នាយដង្គំ ស្រុក សៀមរាប ខេត្តសៀមរាប បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៥០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **អ៊ឹម ប៊ុនហាំ** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម_អាជីវកម្មលើតាំង

ដែលបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបាន យ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើ ពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៦៩ ឧក.ប្រក. ចុះ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **អ៊ុំ ហេង** ជនជាតិ ខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤២៧៦៧ ភ.ព ចុះថ្ងៃទី ១៨-៥-៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៧ ផ្លូវលេខ ៤២៨ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្ម ផលិតទឹកទឹក ស៊ីអ៊ីវខាប់ ទឹកម្ទេស និងទឹកសៀង «សុវណ្ណភូមិ»នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **អ៊ុំ ហេង** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលទឹកស៊ីអ៊ីវខាប់ សញ្ញា «រូបកិន្នរី» និង ទឹកស៊ីអ៊ីវជូរសញ្ញា «រូបតុក្កតា » ទឹកម្ទេសសញ្ញា «រូបនាគ »និងទឹកសៀង សញ្ញា «រូបពេជ្រ » ស្របតាមគំរូ សញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើ ពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម នស.រកម ០១៨៦-០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៨៦

- បានឃើញការចាំបាច់របស់ក្រសួងក្នុងការគ្រប់គ្រងទឹកស្អាតនៅតាមខេត្ត ក្រុងទូទាំងប្រទេស

សំរេច

ប្រការ ១ : បង្កើតអង្គភាពមួយឈ្មោះ «អង្គភាពទឹកស្អាត» ស្ថិតនៅក្រោមចំណុះផ្ទាល់របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ២ : «អង្គភាពទឹកស្អាត»មានភារកិច្ចនិងសិទ្ធិអំណាចលើការងារទឹកស្អាតនៅតាមទីក្រុងនៃខេត្ត - ក្រុង ក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែនៅរាជធានីភ្នំពេញដូចតទៅ :

- ដឹកនាំនិងគ្រប់គ្រងការងារទឹកស្អាតដែលមានស្រាប់និងដែលកើតថ្មី ។
- ចេញសេចក្តីណែនាំលំអិតលើការត្រួតពិនិត្យ និងគ្រប់គ្រងកិច្ចដំណើរការ ការងារទឹកស្អាត
- កសាងផែនការបណ្តុះបណ្តាលនិងធ្វើការសំរបសំរួលជាមួយភ្នាក់ងារផ្តល់ជំនួយនានាដើម្បី ធ្វើអោយប្រសើរឡើងនូវសមត្ថភាពនៃដំណើរការរបស់ការងារទឹកស្អាត

ប្រការ ៣ : « អង្គភាពទឹកស្អាត » ត្រូវបានដឹកនាំគ្រប់គ្រងដោយប្រធានមួយរូបដែលអាចអមដោយអនុប្រធានមួយចំនួន និង មានក្រុមការងារជំនាញមួយចំនួនតាមការចាំបាច់ ។

ប្រការ ៤ : អង្គភាពនេះមានអត្ថិភាពក្នុងការរៀបចំ និង អនុវត្តការងាររបស់ខ្លួនរហូតដល់មានការសំរេច ជាថ្មី ។

ប្រការ ៥ : លោកនាយកខុទ្ទកាល័យ លោកប្រធានមន្ទីរ លោកប្រធានគ្រប់នាយកដ្ឋានសេនាធិការ លោកអគ្គាធិការ មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀង ៗ ខ្លួនតាមប្រកាសនេះ ។

ប្រការ ៦ : ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាទៅ ។

* * *

ប្រកាសលេខ ២៩៨ ផក.ប្រក. ចុះ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ហោ គីមសៀង** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ០១៩៣២៥ ប.ប ចុះថ្ងៃទី ២១-៣-៨៦ អាស័យដ្ឋានបច្ចុប្បន្នក្រុមទី ៥ ភូមិ វត្តលៀប សង្កាត់ ចំការសំរោង ទីរួមខេត្ត បាត់ដំបង ខេត្តបាត់ដំបង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០ សេះ នៅក្នុងទីតាំង ភូមិ វ៉ា ឃុំ មោង ស្រុក មោងឫស្សី ខេត្ត បាត់ដំបង ។

ប្រការ ២ : លោក **ហោ គីមសៀង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៩៩ ផក.ប្រក. ចុះ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **តាន់ ម៉ាលី** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា អត្តសញ្ញាណប័ណ្ណលេខ ១៥២១៨៦ ភ.ព ចុះថ្ងៃទី ១៥-៩-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៨ ផ្លូវលេខ ១៧៣ សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១០០ សេះ នៅក្នុងទីតាំង ភូមិថ្មគោល ឃុំតាពូង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ប្រការ ២ : អ្នកស្រី **តាន់ ម៉ាលី** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម_អាជីវកម្មលើទីតាំងដូចបានកំណត់ ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើង ។

* * *

ប្រកាសលេខ ៣០០ ឧក.ប្រក.ចុះ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **អ៊ុត សំហេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២៩៦៤៧ ភ.ព ចុះថ្ងៃទី ០៩-០១-៨៥ ជាប្រធាន អាស័យដ្ឋាន បច្ចុប្បន្ន ផ្ទះលេខ ៤៩ ផ្លូវលេខ ៩៥ សង្កាត់បឹងកេងកងទី១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បើកដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ១៥០ សេះ នៅក្នុងទីតាំង ភូមិសំរោង សង្កាត់សំរោងក្រោម ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **អ៊ុត សំហេង** ត្រូវរៀបចំរោងម៉ាស៊ីនកិនស្រូវរបស់ខ្លួនអោយស្រេចជាស្ថាពរក្នុងរយៈពេល ៦ ខែ យ៉ាងយូរ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសរយៈពេលកំណត់ប្រកាសនេះត្រូវចាត់ទុកជាមោឃៈ ។

ប្រការ ៣ : លោក **អ៊ុត សំហេង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដែលបានកំ ណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់

មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣០១ ឧក.ប្រក.ចុះ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **ហ៊ុន ទិបុល** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១១៥៦៩ ប.ប ចុះថ្ងៃទី ១៤-០១-៨៦ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នក្រុមទី ១៩ ភូមិព្រៃកមហាទេព ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បើកដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនតំលាំង ១២០ សេះ នៅក្នុងទីតាំង ភូមិ ព្រៃកូនសេក ឃុំអូរចារ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ហ៊ុន ទិបុល** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាស លេខ ៣០២ ឧក .ប្រក ចុះ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ខា ស** ជាប្រធានរោងម៉ាស៊ីនកិនស្រូវដែលមានទីតាំងនៅភូមិមោង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ផ្ទេរភារកិច្ចគ្រប់

គ្រង ជូនលោក ចៅ សឿន វិញ ។

ប្រការ ២ : ទទួលស្គាល់លោក **ចៅ សឿន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៧៤៦៦៩ ប.ប ចុះថ្ងៃទី១៣-១០-៨៧ អាស័យដ្ឋានបច្ចុប្បន្នភូមិរតនៈ ឃុំស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ជាប្រធានរោងម៉ាស៊ីនកិនស្រូវ ដែលមានទីតាំង ដូចមានចែងក្នុងប្រការ ១ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣០៣ ឧក.ប្រក. ចុះ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **សេខ សារឿន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៣៥៤៨០ ភ.ព ចុះថ្ងៃទី១១-០១-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៣៤ ផ្លូវលេខ ២០៥ សង្កាត់ទូលស្វាយព្រៃទី ២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតទឹក ស៊ីអ៊ីវខាប់សញ្ញា «មេអំបៅ» នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក សេខ សារឿន ត្រូវបានអនុញ្ញាតអោយផលិតនូវផលិតផលបួនមុខគឺ «ស៊ីអ៊ីវខាប់ពិសេស» «ទឹកម្ទេស» «សៀងម្ទេស» និង «ទឹកខ្ទិះបារាំង» ស្របតាមគំរូ និង ផ្លាកសញ្ញា ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាព

ប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣០៤ ឧក.ប្រក. ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ស៊ឹម ស៊ុយតាំង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៧១៤៨៣ ភ.ព ចុះថ្ងៃទី ២៥-២-៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១៩៥ អឺ០ មហា វិថីព្រះមុនីវង្ស សង្កាត់មនោរម្យ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បើកដំណើការសិប្បកម្មស្រាកែ ថ្នៃ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ស៊ឹម ស៊ុនតាំង** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលស្រាកែថ្នៃចំនួន ១ មុខគឺ ស្រាសញ្ញា«នាងខ្មៅ »ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣០៥ ឧក.ប្រក. ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយឧស្សាហកម្មតូចផលិតចំណីសត្វដែលមានលោក **អ៊ុង វស្នីសាម៉ាត** ជនជាតិ ថៃ កាន់លិខិតឆ្លងដែន(PASSPORT) លេខ អា ២៣០៣៧០ ចុះថ្ងៃទី ០៩–៦–៩៥ ជាប្រធាន អាស័យដ្ឋាន បច្ចុប្បន្ន

ក្រុមទី ១៦ សង្កាត់លេខ ១ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ បើកដំណើរការផលិតកម្ម នៅក្នុងទីតាំងដូច អាស័យដ្ឋានខាងលើ ។-

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣០៦ ឧក.ប្រក ចុះ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **លី ច្រឹម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៤៣៦៩២ ភ.ព ចុះថ្ងៃទី០៧-៣-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៦២ អឺ០ ផ្លូវលេខ ១១០ ក្រុមទី ៤១ សង្កាត់ ផ្សារចាស់ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បើកដំណើរការឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធ សញ្ញា «មុដពេជ្រ» នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **លី ច្រឹម** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលទឹក បរិសុទ្ធ សញ្ញា «មុដពេជ្រ» ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

២ [illegible] អប់រំ យុវជន

និងកីឡា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣០១ អយក.ប្រក

ស្តីពីកា[illegible]សាលាបឋមសិក្សា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១_១១_៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ក្រច. ចុះថ្ងៃទី ២០_១១_៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- បានឃើញអនុក្រឹត្យលេខ ១៩អនក្រ. ចុះថ្ងៃទី ២៥_១០_៨៦ ស្តីពីការកំណត់បទដ្ឋាន ប្រើ ប្រាស់ក្របខ័ណ្ឌ សំរាប់អង្គភាពអប់រំនានា
- បានពិនិត្យលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជននិងកីឡា ខេត្តបន្ទាយមានជ័យ លេខ ៦៦ អយក.ខចទម. ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៦
- តាមយោបល់ឯកភាព របស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សម្រេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡា ខេត្តបន្ទាយមានជ័យ ផ្តាច់ :
១_សាលាឧបសម្ព័ន្ធ តាផូ២
២_សាលាឧបសម្ព័ន្ធ ពង្រត់ស្រី
៣_សាលាឧបសម្ព័ន្ធ បន្ទាត់បោះ
ចេញពីសាលាបឋមសិក្សា តាផូ១ មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ។

ប្រការ ២ : សាលាបឋមសិក្សាដូចមានរាយនាមខាងលើ ត្រូវដឹកនាំដោយនាយកបង្រៀន ១ រូប ស្របតាម បទដ្ឋានក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក មានសិទ្ធិបើកប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរក្រសួងអប់រំយុវជននិងកីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែន ការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជននិង កីឡាខេត្តបន្ទាយមានជ័យ ប្រធានការិយាល័យអប់រំ យុវជននិងកីឡាស្រុកស្វាយចេក នាយកសាលាបឋមសិក្សាតាផូ២ នាយកសាលាបឋមសិក្សាពង្រតាស្រី នាយកសាលាបឋមសិក្សាបន្ទាត់បោះ មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ_រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
គា សាហាន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣១៣ អយក.ប្រក

ស្តីពីការប្តូរឈ្មោះ អនុវិទ្យាល័យទីរួមខេត្តបាត់ដំបង ទៅជា

" អនុវិទ្យាល័យ សោ ហ៊ី " ស្ថិតនៅក្នុងស្រុក ស្វាយប៉ោ ខេត្តបាត់ដំបង

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែល ប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ក្រច. ចុះថ្ងៃទី ២០-១១-៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ។
- យោងលិខិតរបស់មន្ទីរអប់រំ យុវជននិងកីឡា ខេត្តបាត់ដំបងលេខ ១៣៨ អវ. ទរខ. ចុះថ្ងៃទី ១៣-១១-៩៥ ។
- តាមយោបល់ឯកភាព របស់នាយកដ្ឋានចំនេះទូទៅ និងមត្តេយ្យសិក្សា ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះ អនុវិទ្យាល័យ ទីរួមខេត្តបាត់ដំបង បច្ចុប្បន្នទៅជា "អនុវិទ្យាល័យ**សោ ហ៊ី** " ចាប់ពីបវេសនកាលឆ្នាំសិក្សា ១៩៩៥-៩៦ តទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជា និរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំនេះទូទៅនិងមត្តេយ្យសិក្សា ប្រធាន នាយកដ្ឋានចាត់តាំង និងប្រធាននាយកដ្ឋានផែនការនិងហិរញ្ញកិច្ចនៃ

ក្រសួង អប់រំ យុវជននិងកីឡា ប្រធានមន្ទីរអប់រំ
យុវជននិងកីឡាខេត្តបាត់ដំបង និង នាយកអនុវិទ្យាល័យ សោ ហ៊ី
មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
តុល ឡោះ

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៥៧០ រៀល